# ៦ ឯកសារពិគ្រោះ

# ឧបករណ៍គណនេយ្យភាពសង្គម

# ការត្រួតពិនិត្យលទ្ធកម្ម



# ម៉ូឌុល៨: ឧបករណ៍គណនេយ្យភាពសង្គម

# មេរៀន:

# ការត្រួតពិនិត្យលទ្ធកម្ម

មាតិកា ទំព័រ


១-និយមន័យ ........ ៣

២-សារៈសំខាន់នៃការចូលរួមរបស់ពលរដ្ឋក្នុងលទ្ធកម្មសាធារណៈ ........ ៣

៣-ដំណើរការលទ្ធកម្មសាធារណៈ ........ ៤

៤-ការលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋក្នុងដំណើរការលទ្ធកម្មសាធារណៈ ........ ៦

៥-គន្លឹះសំខាន់ៗនៃមេរៀន ........ ៨

# ការត្រួតពិនិត្យលទ្ធកម្ម

## ១- និយមន័យ

លទ្ធកម្ម សំដៅដល់ការទិញ ទំនិញនិងសេវាកម្ម តាមរយៈការជួលអ្នកទទួលការ ឬទីប្រឹក្សា ដើម្បីផ្ដល់សេវាកម្ម។

ធនធានចាំបាច់នានាដែលប្រើក្នុងការផ្ដល់សេវាត្រូវមានតម្លៃទាប និងមានគុណភាពអាចទទួលយកបាន។ ចំណុចនេះអាចសម្រេចទៅបានអាស្រ័យប្រព័ន្ធលទ្ធកម្មសាធារណៈ ដែលផ្អែកលើគោលការណ៍ប្រកួតប្រជែងទីផ្សារ។

យោងតាមលោក Westri និង (១៩៧៨) បានលើកឡើងថា លទ្ធកម្មសាធារណៈ ដែលមានប្រសិទ្ធភាព គឺអាស្រ័យលើកត្តា ដូចខាងក្រោម:

១- កំណត់ដោយបទដ្ឋានគតិយុត្តអំពី លទ្ធកម្មសាធារណៈ ដូចជា: ច្បាប់ លក្ខន្តិកៈ អនុក្រិត និងគោលនយោបាយ (ឧទាហរណ៍: អាទិភាពចំពោះអ្នកផ្ដល់សេវាក្នុងស្រុកឬមូលដ្ឋាន)។

២- ផ្ដល់មូលនិធិដល់លទ្ធកម្មដែលរដ្ឋាភិបាលពេញចិត្ត

៣- ធ្វើអធិការកិច្ចដោយប្រព័ន្ធសវនកម្មរបស់រដ្ឋ

៤- រដ្ឋាភិបាលទទួលខុសត្រូវការ ធ្វើកិច្ចសន្យាជាមួយភាគីទី៣

៥- អ្នកទទួលការត្រូវបង្កើតដោយមានលក្ខន្តិកៈ ឬ អនុវត្តដូចជាវិស័យឯកជន

នារយៈកាលប៉ុន្មានឆ្នាំនេះ តួនាទីរបស់ក្រុមប្រជាពលរដ្ឋត្រូវបានគេទទួលស្គាល់យ៉ាងទូលំ ទូលាយក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ជាពិសេសក្នុងការធ្វើឱ្យមាន តម្លាភាព និងគណនេយ្យភាព នៃដំណើរការលទ្ធកម្មសាធារណៈ។

## ២- សារៈសំខាន់នៃការចូលរួមរបស់ពលរដ្ឋក្នុងលទ្ធកម្មសាធារណៈ

អង្គការតម្លាភាពអន្តរជាតិ និងអង្គការសង្គមស៊ីវិលនានាលើសាកលលោកដែលធ្វើការក្នុងការ ប្រឆាំងនឹងអំពើពុករលួយ បានរកឃើញថាក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន ទឹកប្រាក់ប្រមាណ ៤២០ ពាន់លានដុល្លារ បានបាត់បង់ជារៀងរាល់ឆ្នាំ ដោយសារកិច្ចការលទ្ធកម្ម (WBI ២០០៩)។ បញ្ជាសរបញ្ជាក់ថា លទ្ធកម្មជាកត្តាសំខាន់ក្នុងការធ្វើមានអំពើពុករលួយ។

ដើម្បីឆ្លើយតបនឹងបញ្ហានេះ ការត្រួតពិនិត្យលទ្ធកម្មជាដំណើរការដែលពលរដ្ឋត្រូវបានបណ្តុះបណ្តាលឱ្យត្រួតពិនិត្យមើលគ្រប់ដំណាក់ការរបស់ដំណើរការលទ្ធកម្មសាធារណៈ។ ពលរដ្ឋនិងក្រុមពលរដ្ឋអាចចូលរួមពិនិត្យតាមដាននៅគ្រប់ដំណាក់កាលទាំងអស់នៃលទ្ធកម្មសាធារណៈ។ ការត្រួតពិនិត្យលទ្ធកម្មនេះជាទូទៅធ្វើឡើងតាមរយៈការសម្របសម្រួលដោយពិភាក្សាជាច្រើនលើកជាមួយរដ្ឋាភិបាល ឬតាមរយៈការប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសគណនេយ្យភាពសង្គមសម្រាប់ត្រួតពិនិត្យចំណាយសាធារណៈនិងការផ្តល់សេវា។

ពលរដ្ឋអាចជួយរដ្ឋាភិបាលឱ្យអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃលទ្ធកម្មដោយប្រសិទ្ធភាព ប្រសិនបើភ្នាក់ងារសវនកម្មផ្ទៃក្នុងរបស់រដ្ឋាភិបាលផ្តល់ឱកាសឱ្យពួកគាត់អាចទទួលបានឯកសារលទ្ធកម្ម។ ទោះជាយ៉ាងនេះក្តី សហប្រតិបត្តិការ និងភាពស្របច្បាប់របស់ក្រុមពលរដ្ឋមានសារៈសំខាន់ណាស់សម្រាប់ទទួលបានការជឿជាក់ និងទំនុកចិត្តរបស់ស្ថាប័នសវនកម្មសាធារណៈដើម្បីទទួលបានឯកសារលទ្ធកម្មដែលពួកគេមាន។ ដូចគ្នានេះដែរ ការសហប្រតិបត្តិការល្អជួយឱ្យភ្នាក់ងាររដ្ឋាភិបាលរឃើញភាពមិនប្រក្រតីក្នុងដំណើរការលទ្ធកម្ម។

៣- ដំណើរការលទ្ធកម្មសាធារណៈ

ការចូលរួមរបស់ពលរដ្ឋកើតឡើងនៅគ្រប់ដំណាក់ទាំងអស់នៃដំណើរការលទ្ធកម្មសាធារណៈ។ ដំណើរការលទ្ធកម្មអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ជាទូទៅ ដំណើរការលទ្ធកម្មគួរតែមានដំណាក់កាលដូចខាងក្រោមនេះៈ ការរៀបផែនការលទ្ធកម្ម ការរៀបចំលទ្ធកម្ម ការផ្សព្វផ្សាយ ពាណិជ្ជកម្ម លក្ខណៈសម្បត្តិមុនការវាយតម្លៃការដេញថ្លៃ ការផ្តល់កិច្ចសន្យា និង ការអនុវត្តកិច្ចសន្យា។ ការត្រួតពិនិត្យគួរត្រូវបានអនុវត្តពេញមួយដំណើរការទាំងមូល ដោយដំណាក់ និមួយៗមានចន្លោះប្រហោងសម្រាប់ធ្វើការកិបកេងនិងក្លែងបន្លំ (WBI 2009).

ដំណើរការលទ្ធកម្ម ( *Source: Ed Campos (2006) A Powerpoint Presentation titled "Public Procurement and Corruption: What Have We Learned Thus Far" downloaded from http://www1.worldbank.org/publicsector/pe/pfma06/page8.htm*

| | |
|---|---|
| **ក. ការរៀបចំផែនការលទ្ធកម្ម** | ជាដំណាក់ដែលភ្នាក់ងារវាយតម្លៃតម្រូវការ និងកំណត់ទំនិញ និងសេវា ដែលត្រូវស្នើ។ |
| **ខ. ការរៀបចំលទ្ធកម្ម** | ភ្នាក់ងារគួររៀបរាប់សម្ភារៈដែលត្រូវទិញនិងលក្ខណៈវិនិច្ឆ័យឱ្យបានច្បាស់លាស់និងមិនលំអៀង។ |
| **គ. ការផ្សព្វផ្សាយព័ត៌មានពីការដេញថ្លៃ** | ត្រូវជូនដំណឹងដល់សាធារណជនឱ្យបានដឹងពីការផ្ដល់ឱកាសស្មើគ្នាក្នុងការចូលរួមដេញថ្លៃ។ |
| **ឃ. បុរេវិនិច្ឆ័យ** | កំណត់គុណភាពអ្នកចូលរួមដេញថ្លៃ ផ្អែកលើ សមត្ថភាព បទពិសោធន៍ ធនធាន ឬ លក្ខណៈវិនិច្ឆ័យផ្សេងៗ។ |
| **ង.ការវាយតម្លៃការដេញថ្លៃ** | វាយតម្លៃការដេញថ្លៃដើម្បីរកឱ្យឃើញ ថាការដេញថ្លៃណាខ្លះ ដែលបាន បំពេញតាមលក្ខខណ្ឌ។ |
| **ច. ការផ្ដល់កិច្ចសន្យា** | អ្នកដេញថ្លៃនឹងទទួលជោគជ័យ ផ្អែកលើ (១)បំពេញរាល់ឯកសារដែលត្រូវការ និង(២) តំលៃទាបបំផុត។ |
| **ជ. ការអនុវត្តកិច្ចសន្យា** | ការផ្ដល់កិច្ចសន្យានឹងអនុវត្តដោយអនុឡោមតាមការកំណត់ដូចមានចែងក្នុងការដេញថ្លៃ។ |

## ដំណើរការរៀបចំបញ្ជីបុរេវិនិច្ឆ័យគុណភាពអ្នកទទួលការក្នុងសៀវភៅភីម



### ៤- ការលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋក្នុងដំណើរការលទ្ធកម្មសាធារណៈ:

តារាងខាងក្រោមនេះសង្ខេបពីបញ្ហាដែលតែងតែជួបប្រទះក្នុងដំណាក់និមួយៗនៃលទ្ធកម្ម សាធារណៈនិងការចូលរបស់ពលរដ្ឋ។

| **ដំណាក់កាលលទ្ធកម្មសាធារណៈ** | **បញ្ហា** | **ចំណុចចាប់ផ្តើមការចូលរួមរបស់ពលរដ្ឋ** |
|---|---|---|
| ការរៀបផែនការលទ្ធកម្ម | - តម្រូវការគឺជាការប៉ាន់ ស្មានមិនមែនជាក់លាក់<br>- ការទិញមិនត្រូវតាមភាពជាក់ស្តែង ដោយសារភាពបន្ទាន់ និង មានរយៈពេលខ្លីនៃដំណើរការដេញថ្លៃ<br>- ការបែងចែកធនធានមិនត្រឹមត្រូវ | - ការចូលរួមរបស់សាធារណជនតាមរយៈការប្រជុំសហគមន៍ ដើម្បីត្រួតពិនិត្យតម្រូវការ លើកកម្ពស់គណនេយ្យភាព និងកំណត់សម្ភារដែលចាំបាច់ឬមិនចាំបាច់នៃទំនិញឬសេវា ត្រូវទិញ<br>- ការផ្សព្វផ្សាយព័ត៌មានដោយភ្នាក់ងាររដ្ឋាភិបាលពីព័ត៌មានមានពាក់ពន្ធ័តាមរយៈក្ការផ្សាយព័ត៌មាន វិទ្យុ កាសែត ឬ អ៊ីនធឺណិត |
| ការរៀបចំលទ្ធកម្ម | - ការបរិយាយតាមលក្ខណៈបច្ចេកទេសមានភាពទន់ខ្សោយ | - ការចូលរួមរបស់សាធារណជនដើម្បីពិភាក្សារៀបចំដំណើរការ និងលើកឡើង |

| | | |
|---|---|---|
| | – ការិយាល័យគ្រប់គ្រងតែមួយទទួលខុសត្រូវលើការពិនិត្យលើ ការរៀបចំរបស់អ្នកទទួលការច្រើន<br>– ខ្វះការប្រកួតប្រជែង | នូវកង្វល់ ឬ ការបម្រុងទុករបស់គម្រោង<br>– ការផ្សព្វផ្សាយព័ត៌មានដោយភ្នាក់ងាររដ្ឋាភិបាលពីព័ត៌មានមានពាក់ពន្ធ័នានា |
| ការផ្សព្វផ្សាយព័ត៌មាន ពីការដេញថ្លៃ | – ការផ្សព្វផ្សាយមានកម្រិត ឬ មិនមានប្រសិទ្ធភាព | – ចាត់អទិភាពផ្សព្វផ្សាយ ដោយបោះពុម្ពផ្សាយ<br>ដែលមនុស្សភាគច្រើនអាចទទួលបាន |
| បុរេវិនិច្ឆ័យ | – អ្នកដែលនឹងចូលរួមដេញថ្លៃនាពេលអនាគត ទទួលបានព័ត៌មានលម្អិត ហើយយល់ថាដំណើរការបុរេវិនិច្ឆ័យមានភាពលំអៀង<br>– លក្ខខណ្ឌដែលបានបង្កើតឡើងលំអៀងទៅអ្នកទទួលការម្នាក់ឬក្រុមអ្នកទទួលការជាកលាក់ណាមួយ<br>– ដំណើរការមានរយៈពេលយូរផ្តល់ឱកាសឱ្យមានអំពើពុករលួយ | – ការផ្សព្វផ្សាយព័ត៌មានស្តីពីលក្ខខណ្ឌនិងដំណើរ ការនៃការដេញថ្លៃ<br>ជាសាធារណៈយ៉ាងទូលំទូលាយ |
| ការវាយតម្លៃការដេញថ្លៃ | – អ្នកសំរេចចិត្តមានសិទ្ធិសំរេចយ៉ាងទូលំទូលាយ<br>– មាននិន្នាការស្វែងរកអន្តរាគមន៍តាមផ្លូវច្បាប់<br>– ភាពមិនប្រក្រតី ឬការពន្យាពេលក្នុងការវាយតម្លៃការដេញថ្លៃ<br>– ការមិនទុកឱកាសឱ្យមានការសួរបញ្ជាក់ | – ការផ្សព្វផ្សាយនិងទទួលបានព័ត៌មានពីអ្នកដេញថ្លៃនិងដំណើរការវាយតម្លៃការដេញថ្លៃជាសាធារណៈ |
| ការផ្តល់កិច្ចសន្យា | – វិធានឬគោលការណ៍មិនច្បាស់លាស់<br>– ការបដិសេធរាល់ការដេញថ្លៃទាំងអស់ | – ការផ្សព្វផ្សាយព័ត៌មានដោយភ្នាក់ងាររដ្ឋាភិបាលពីព័ត៌មានមានពាក់ពន្ធ័<br>– ការចូលរួមរបស់សាធារណៈ តាមរយៈក្រុមសង្គមស៊ីវិល ដែលជាអ្នកសង្កេតការណ៍ភាគីទីព ក្នុងដំណើរការវាយតម្លៃការដេញថ្លៃដើម្បីធានាមានភាពត្រឹមត្រូវ |
| ការអនុវត្តកិច្ចសន្យា | – ការត្រួតពិនិត្យ និងអនុវត្តមិនបានល្អ<br>– កិច្ចសន្យាអាចឱ្យចចារឡើងវិញ | – ឧបករណ៍វាយតម្លៃការអនុវត្តដោយមានការចូលរួម<br>– មានភាពច្បាស់លាស់និងមានដែន |

| | | |
|---|---|---|
| | | កំណត់ដែលត្រូវបានបង្កើតឡើងជាមុន ក្នុងកិច្ចសន្យាផ្លាស់ប្តូរលំដាប់លំដោយ |

## ៥- គន្លឹះសំខាន់ៗនៃមេរៀន

ការត្រួតពិនិត្យលទ្ធកម្ម គឺជាដំណើរការនៃការវិភាគឯកសារលទ្ធកម្មនិងឱ្យភ្នាក់ងាររបស់រដ្ឋាភិបាល មានគណនេយ្យភាពចំពោះសកម្មភាពលទ្ធកម្មរបស់ពួកគាត់។

ការត្រួតពិនិត្យលទ្ធកម្មអាចកាត់បន្ថយអំពើពុករលួយក្នុងលទ្ធកម្មសាធារណៈ ដោយពង្រឹងព័ត៌មានតម្លាភាព និងគណនេយ្យភាព។

ដំណាក់ការដំណើរការត្រួតពិនិត្យលទ្ធកម្មសាធារណៈមានដូចខាងក្រោម៖ ផែនការលទ្ធកម្ម ការរៀបចំលទ្ធកម្ម ការផ្សព្វផ្សាយពាណិជ្ជកម្ម លក្ខណៈសម្បត្តិមុន ការវាយតម្លៃការដេញថ្លៃ ការផ្តល់កិច្ចសន្យា និង ការអនុវត្តកិច្ចសន្យា។

ការត្រួតពិនិត្យលទ្ធកម្មមានឧបករណ៍ និង បច្ចេកទេសដូចដែលអនុវត្តក្នុងដំណាក់ផ្សេងៗនៃ ដំណើរការលទ្ធកម្មមួយចំនួន។ ការត្រួតពិនិត្យរួមមានឧបករណ៍ចូលរួមតាមដានចំណាយ ឧបករណ៍ត្រួតពិនិត្យ ការអនុវត្តដោយមានការចូលរួម កតិកាសុចរិតភាព ក្រុមតាមដានលទ្ធកម្ម និង លទ្ធកម្មតាម ប្រពន្ធ័អេ ឡិចត្រូនិច។

បញ្ហាប្រឈមសំខាន់ៗមួយចំនួនក្នុងការត្រួតពិនិត្យលទ្ធកម្មដោយមានការចូលរួមមានដូចជា៖

១. ខ្វះក្របខណ្ឌស្របច្បាប់
២. ប្រពន្ធ័រដ្ឋបាលស្ថិតក្រោមសម្ពាធនយោបាយ និង មានភាពទន់ខ្សោយ
៣. ខ្វះតម្លាភាព និងព័ត៌មាន
៤. ខ្វះជំនឿទុកចិត្ត
៥. ខ្វះការគាំទ្រពីសហគមន៍